## បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity)

អនុសញ្ញា Hague ស្តីពីច្បាប់សង្គ្រាមឆ្នាំ ១៨៩៩ (Convention on the Laws of Warfare) បានយោងដល់ទ្រឹស្តីមនុស្សជាតិ (humanity) ឬ Martens Clause។ ក្រោយមក ក្នុងឆ្នាំ ១៩៥១ ប្រទេសមួយចំនួនដូចជា បារាំង បានប្រើពាក្យ «ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» (crime against humanity) យោងដល់ការសម្លាប់ជនជាតិ Armenians នៅក្នុងចក្រភព Ottoman។ ក្រោយសង្គ្រាមលោកលើកទី១ សន្ធិសញ្ញា Versailles ឆ្នាំ១៩១៩ មិនបានដាក់បញ្ចូល បទល្មើសប្រឆាំងនឹងច្បាប់មនុស្សជាតិ (offense against the law of humanity) ដោយសារមានជំទាស់ពីសហរដ្ឋអាមេរិក។

តុលាការ Nuremburg បានអះអាងថា បទល្មើសប្រព្រឹត្តមួយចំនួន ប្រព្រឹត្តដោយអាជ្ញាធរអ៊ីត្លែរទៅលើប្រជាជនអាឡឺម៉ង់ខ្លួនឯង។ នាពេលមុន បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានប្រព្រឹត្តក្នុងពេលមានសង្គ្រាម ក៏ប៉ុន្តែ តាំងពី ឆ្នាំ ១៩៤៥ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចត្រូវបានប្រព្រឹត្តក្នុងពេលសន្តិភាព ដូចនេះចំណងភ្ជាប់ដូចនេះ លែងតម្រូវឲ្យមានហើយ (war nexus)។ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាប់ទាក់ទងនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ធាតុផ្សំទូទៅនៃបទឧក្រិដ្ឋ (chapeau elements) នេះមាន៖ ការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ (widespread or systematic attack) លើជនស៊ីវិល។ នេះនឹងមិនរាប់បញ្ចូលនូវ ការវាយប្រហារម្តងម្កាល។ ទម្រង់នៃការវាយប្រហារនេះ នាំឲ្យមានជនរងគ្រោះ និងផលប៉ះពាល់ជាច្រើន ដែលធ្វើឲ្យ ពិភពលោករំជួលចិត្ត។

មានបទល្មើសដោយឡែកៗ ជាច្រើនស្ថិតនៅក្រោមបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា៖ អំពើអមនុស្សធម៌ផ្សេងទៀត (other inhuman treatment) ការធ្វើទុក្ខបុកម្នេញ (persecution) ការមានគ៌ដោយបង្ខំ (forced pregnancy) ការបាត់ខ្លួនដោយបង្ខំ (enforced disappearance of persons) និង apartheid (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 284-288)។